# សន្ធិសញ្ញា

## ស្ដីពី

## បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា
## និងសាធារណរដ្ឋប្រជាមានិតចិន

# ព្រះរាជក្រម

នស/រកម/០៧០០/០៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិ - បត្តិការអន្តរជាតិ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែល ព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ នាសម័យ ប្រជុំពេញអង្គលើកទី ៣ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលធ្វើនៅទីក្រុងប៉េកាំង នាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ហត្ថលេខា**

**ហោ ណាំហុង**

# សន្ធិសញ្ញា
# ស្តីពី បត្យាប័ន
# រវាង
# ព្រះរាជាណាចក្រកម្ពុជា
# និង
# សាធារណរដ្ឋប្រជាមានិតចិន

*****************

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ដែលតទៅនេះកំណត់ហៅថា "ភាគីចុះកិច្ចព្រមព្រៀង"

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និង ផលប្រយោជន៍ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន

បានព្រមព្រៀងគ្នាដូចតទៅ :

## ប្រការទី ១
## ភារកិច្ចត្រូវធ្វើបត្យាប័ន

យោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជំរះក្តី ឬ ដើម្បីអោយទទួលទោស ឬ អនុវត្តន៍ទណ្ឌកម្ម តាមទោសកំណត់នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ ។

## ប្រការទី ២
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១.ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬ ការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

២.កាលណាមានសំណើបត្យាប័នពាក់ព័ន្ធដល់បុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬ ការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀត ធ្វើឡើងដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួលដូចមានចែងក្នុងសាលក្រម នៅសល់យ៉ាងតិចបំផុត ៦ ខែទៀត ។

៣.ក្នុងស្មារតីប្រការនេះ ការកំណត់ថាបទល្មើសណាមួយ ជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថាអង្គច្បាប់នៃភាគីចុះកិច្ចព្រមព្រៀង ចាត់ទុកអំពើដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬ កំណត់បទល្មើសដោយពាក្យពេចន៍ដូចគ្នានោះទេ ។

៤.កាលណាបត្យាប័នត្រូវបានផ្តល់អោយ ក្នុងស្មារតីនៃបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័ននេះក៏អាចផ្តល់អោយចំពោះបទល្មើសផ្សេងទៀត ដែលចែងក្នុងសំណើបត្យាប័នដដែលនេះ ហើយដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើបត្យាប័ន លើកលែងតែរយៈពេលផ្តន្ទាទោស ឬ ឃុំឃាំង ដែលមានចែងក្នុងកថាខ័ណ្ឌទី ១ និង ២ របស់ប្រការនេះ ។

## ប្រការទី ៣
## មូលដ្ឋាននៃការបដិសេធដាច់ខាត

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័ននឹងមិនអនុញ្ញាតិអោយធ្វើបានឡើយ ក្នុងករណីណាមួយដូចខាងក្រោមនេះ :

១.ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកគ្រួសារនៃវរជនទាំងនោះ ។

២.ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ ត្រូវបានគេចាត់ទុកថាបានធ្វើអោយប៉ះពាល់ការសំអាងដែលពោលខាងលើ ។

៣.បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន តាមច្បាប់របស់ភាគីដាក់សំណើ គឺជាបទល្មើសយោធាសុទ្ធសាធ ។

៤.ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរាំងស្ទះដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល ។

៥.ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦.ប្រសិនបើសាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយជនជាប់ទោសពុំបានទទួលពត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬ គ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬ គ្មានឱកាសដើម្បីអោយសំណុំរឿងក្តីរបស់ខ្លួនបានត្រូវជំនុំជំរះឡើងវិញដោយមានវត្តមានរបស់ខ្លួន ។

## ប្រការទី ៤
## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័នអាចបដិសេធបានក្នុងករណីណាមួយ ដូចខាងក្រោមនេះ :

១.យោងទៅតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុរបស់សំណើបត្យាប័ន ហើយនឹងត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែលត្រូវស្នើសុំដោយខ្លួនឯង ។

២.ភាគីទទួលសំណើ កំពុងតែធ្វើនីតិវិធីជំនុំជំរះក្តី លើជនដែលត្រូវស្នើសុំចំពោះបទល្មើសដដែលនេះ ។

៣.ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍ស្របច្បាប់របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមិតភាព នឹងទស្សនៈវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ ។

៤.ប្រសិនបើបុគ្គលដែលត្រូវស្នើអោយធ្វើបត្យាប័ន ត្រូវបានគេកាត់ទោស ឬក៏ នឹងត្រូវចូលសវនាការ ឬ កាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការ ឬ សាលាជំរះក្តីពិសេស ឬ បណ្តោះអាសន្នណាមួយ ។

## ប្រការទី ៥
## បត្យាប័នចំពោះពលរដ្ឋសាមី

១.ភាគីចុះកិច្ចព្រមព្រៀងម្ខាងៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន ។

២.ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់អោយ ដោយយោងទៅលើកថាខ័ណ្ឌទី១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និង វត្ថុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ ។

៣. ទោះបីកថាខ័ណ្ឌទី២នៃមាត្រានេះ បានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់ត្រូវបញ្ជូនបណ្ដឹងក្ដីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

## ប្រការទី ៦
## វិធីផ្ដល់ពត៌មាន

ក្នុងស្មារតីនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈផ្លូវទូតវៀរលែងតែមានបទបញ្ញត្តិផ្សេងចែងក្នុងសន្ធិសញ្ញានេះ ។

## ប្រការទី ៧
## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ :

ក. ឯកសារ, សេចក្ដីបញ្ជាក់ ឬ ភស្តុតាងផ្សេងទៀត មានលក្ខណៈគ្រប់គ្រាន់សំរាប់ពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ,

ខ. សេចក្ដីបញ្ជាក់ លើកអង្គហេតុនៃបណ្ដឹងក្ដី,

គ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន,

ឃ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការផ្ដន្ទាទោសទៅលើបទល្មើស និង

ង. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬ ការអនុវត្តនីទណ្ឌកម្ម ចំពោះបទល្មើសប្រសិនបើមាន ។

២. សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវស្នើសុំដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវ :

ក. សេចក្ដីចំលងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតរបស់ភាគីដាក់សំណើ ។

ខ. ភស្តុតាងដែលអាចសំអាងបានសំរាប់ការចាប់ខ្លួន និង ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះក្តីរបស់ជននោះ ដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ខ្លួនមែន ។

៣. ជាបន្ថែមទៅលើចំណុចទាំងឡាយ ដែលចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ កាលណាសំណើបត្យាប័នទាក់ទងទៅនឹងជនដែលបានត្រូវកំណត់ទោសរួចហើយ សំណើនេះត្រូវភ្ជាប់មកជាមួយនូវ :

ក. សេចក្តីចំលងនៃសាលក្រមរបស់តុលាការនៃភាគីដាក់សំណើ,

ខ. ភស្តុតាងបញ្ជាក់ថា ជនដែលត្រូវស្នើសុំ ពិតជាជនដែលកំណត់ក្នុងសាលក្រម,

គ. សេចក្តីបញ្ជាក់បង្ហាញអំពីកំរិតដែលសាលក្រមនោះបានត្រូវអនុវត្តហើយ និង

ឃ. សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលមានសំរាប់បុគ្គលដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬ ក៏ចាត់អោយមានការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ចំពោះករណីដែលជននោះត្រូវបានសំរេចកំបាំងមុខ អោយជាប់ទោស ចំពោះបទល្មើសរបស់គាត់ ។

៤. រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនអោយក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬ បោះត្រាជាផ្លូវការ និង ភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬ ជាភាសាអង់គ្លេស ។

## ប្រការទី ៨
## ពត៌មានបន្ថែម

ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ពត៌មានដែលផ្តល់សំរាប់គាំទ្រសំណើបត្យាប័នពុំមានលក្ខណៈគ្រប់គ្រាន់ ស្របតាមសន្ធិសញ្ញាដែលអនុញ្ញាតអោយធ្វើបត្យាប័នបាន ភាគីនោះអាចស្នើសុំផ្តល់ពត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប ។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនពត៌មានបន្ថែម តាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ។ ប៉ុន្តែភាគីដាក់សំណើ មិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ ។

## ប្រការទី ៩
## ការចាប់ខ្លួនបណ្ដោះអាសន្ន

១. ក្នុងករណីបន្ទាន់ ភាគីចុះកិច្ចព្រមព្រៀងម្ខាង អាចស្នើទៅភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀតអោយធ្វើការចាប់ខ្លួនបណ្ដោះអាសន្ននូវជនដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនជាលាយល័ក្ខអក្សរតាមផ្លូវទូត ឬ តាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ( អាំងទែរប៉ូល )។

២. សំណើសុំខាងលើត្រូវមាន :

- ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ
- ទីកន្លែងដែលជននោះស្ថិតនៅ ប្រសិនបើដឹង
- សេចក្ដីបញ្ជាក់សង្ខេប អំពីដំណើរហេតុនៃបណ្ដឹងក្ដី
- សេចក្ដីបញ្ជាក់ថា មានដីកាចាប់ខ្លួន ឬ សាលក្រមលើជននោះ ដូចមានចែងក្នុងប្រការទី៧ និង
- សេចក្ដីបញ្ជាក់ថា សំណើបត្យាប័នលើជនដែលត្រូវស្នើសុំនឹងត្រូវបញ្ជូនមក តាមក្រោយ ។

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួន ដោយគ្មានបង្អែបង្អង់ ។

៤. ការចាប់ខ្លួនបណ្ដោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបត្យាប័នជាផ្លូវការ និង រាល់ឯកសារសំអាងទាំងឡាយដូចដែលកំណត់ក្នុងប្រការទី៧ ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជនដែលត្រូវសុំ ។ កថាខណ្ឌនេះ មិនត្រូវបានរារាំងដល់លទ្ធភាពក្នុងការដោះលែងដោយមានលក្ខខ័ណ្ឌជនដែលត្រូវស្នើសុំមុនផុតរយៈពេល ៦០ថ្ងៃនេះទេ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាត ឬ ក៏មូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬក៏ ក្នុងករណីដែលភាគីដាក់សំណើលុបចោលនូវសំណើបត្យាប័នរបស់ខ្លួន។

៥. ការបញ្ចប់នូវការចាប់ខ្លួនបណ្ដោះអាសន្នយោងតាមកថាខ័ណ្ឌ៤នៃប្រការនេះ មិនត្រូវមានផលប៉ះពាល់ដល់ការធ្វើបត្យាប័ននូវជនដែលត្រូវស្នើសុំនោះទេប្រសិនបើសំណើបត្យាប័ន

និង រាល់ឯកសារគាំទ្របត្យាប័នដូចមានចែងក្នុងប្រការទី៧ ត្រូវបានផ្តល់អោយក្នុងកាលបរិច្ឆេទក្រោយទៀត ។

## ប្រការទី ១០
## ការសំរេចចិត្តទៅលើការស្នើ

១. ភាគីទទួលសំណើត្រូវអនុវត្តពិនិត្យលើសំណើសុំបត្យាប័ន ស្របតាមនីតិវិធីចែងដោយច្បាប់របស់ខ្លួន នឹងត្រូវជូនពត៌មានយ៉ាងឆាប់រហ័សតាមរយៈផ្លូវទូត ទៅភាគីដាក់សំណើអំពីសេចក្តីសំរេចចិត្តរបស់ខ្លួន ។

២. ការបញ្ជាក់ពីមូលហេតុនៃការបដិសេធទាំងស្រុង ឬ ដោយអន្លើណាមួយលើសំណើសុំបត្យាប័ននោះត្រូវតែផ្តល់ជូន ។

## ប្រការទី ១១
## ការប្រគល់ខ្លួនជនដែលត្រូវបានស្នើសុំ

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និង ភាគីដាក់សំណើត្រូវសំរេច អំពីការអនុវត្តនីបត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ។ ដើម្បីបំណងនេះ ភាគីទទួលសំណើ នឹងជូនពត៌មានដល់ភាគីដាក់សំណើពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន ។

២. លើកលែងតែករណីកថាខ័ណ្ឌ ៣ នៃប្រការនេះ មិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវ បានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល១៥ថ្ងៃក្រោយពីកាលបរិច្ឆេទសំរាប់ការអនុវត្តធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងគ្នារួចហើយ ។ ភាគីទទួលសំណើត្រូវដោះលែងជននោះអោយមានសេរីភាពជាបន្ទាន់ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ ។

៣. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយខកខានពុំបានប្រគល់ ឬ ទទួលជនដែលត្រូវស្នើសុំ ក្នុងថេរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិភាគីម្ខាងទៀត

ត្រូវតែបានជូនពត៌មានពីបញ្ហានេះ ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវសិរបេចជាថ្មីម្តងទៀ តាមការពិគ្រោះគ្នាអំពីការអនុវត្តនីបត្យាប័នម្តងទៀត ហើយបទបញ្ញត្តិនៃកថាខណ្ឌទី ២ នៃប្រការនេះនឹងត្រូវអនុវត្ត ។

## ប្រការទី ១២
## ការពន្យារពេលនៃការប្រគល់ខ្លួន. និង ការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំ កំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជំរះក្តី ឬ កំពុងទទួលទោសក្នុងប្រទេសនៃភាគីទទួលសំណើ អំពីបទល្មើសណាមួយផ្សេងពីបទល្មើសជាកម្មវត្ថុរបស់បត្យាបន៍ ភាគីទទួលសំណើអាចប្រគល់ ឬ ពន្យារការប្រគល់ជននោះរហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវផ្តល់ដំណឹងជូនភាគីដាក់សំណើអំពីការពន្យារពេលនេះ ។

២. យោលទៅតាមធរមាននៃច្បាប់របស់ប្រទេសខ្លួន ក្នុងករណីដែលគេយល់ថា ជនម្នាក់អាចត្រូវធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្នទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខណ្ឌ ដែលបានកំណត់រវាងភាគីទាំងពីរ ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពី ការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិ នៃសន្ធិសញ្ញានេះ ។

## ប្រការទី ១៣
## សំណើបត្យាបន័ធ្វើឡើងដោយរដ្ឋជាច្រើន

ប្រសិនបើសំណើបត្យាប័នចំពោះតែជនម្នាក់ត្រូវបានធ្វើឡើងដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ និងពីរដ្ឋដទៃផ្សេងមួយឬច្រើនទៀតផងនោះ ភាគីទទួលសំណើអាចកំនត់ពីអាទិភាពចំពោះសំណើណាមួយក្នុងចំណោមសំណើបត្យាប័នទាំងនោះ ។

## ប្រការទី ១៤
## វិធានពិសេស

១. ជនដែលត្រូវធ្វើបត្យាបន៍ អនុលោមតាមសន្ធិសញ្ញានេះ មិនត្រូវទទួលការឃុំឃាំង ទទួលការកាត់ក្ដី ឬ ការដាក់ទណ្ឌកម្ម នៅក្នុងដែនដីភាគីដាក់សំណើសំរាប់បទល្មើសផ្សេង ក្រៅពីបទល្មើសដែលបត្យាបន៍បានត្រូវប្រគល់ជូនព្រមទាំងមិនត្រូវធ្វើបត្យាបន៍បញ្ជូនទៅរដ្ឋផ្សេងទៀតដោយភាគីនេះ លើកលែងតែក្នុងករណី :

ក. ជននោះបានចាកចេញពីដែនដីនៃភាគីដាក់សំណើ បន្ទាប់ពីការធ្វើបត្យាបន៍ ហើយបានត្រឡប់មកដែនដីនេះវិញដោយស្ម័គ្រចិត្ត

ខ. ជននោះមិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងរយៈពេល ៣០ថ្ងៃ ដែលទុកឱ្យជននោះមានសិទ្ធិចាកចេញ ឬ

គ. ភាគីទទួលសំណើបានយល់ព្រមឱ្យមានការឃុំឃាំង ការកាត់ក្ដី ឬ ការដាក់ទណ្ឌកម្មចំពោះជននោះពីបទល្មើសផ្សេងក្រៅពីបទល្មើសដែលបានស្នើសុំឱ្យមានបត្យាបន៍ ឬ យល់ព្រមឱ្យមានការធ្វើបត្យាបន៍ទៅរដ្ឋដទៃផ្សេងទៀត ។ ក្នុងស្ថានភាពនេះ ភាគីទទួលសំណើ អាចទាមទារឱ្យផ្ដល់នូវឯកសារ ឬ សេចក្ដីបញ្ជាក់ណាមួយ ដូចមានចែងក្នុងប្រការទី៧ រួមទាំងសេចក្ដីបញ្ជាក់ដែលធ្វើឡើងដោយជនដែលត្រូវធ្វើបត្យាបន៍ ចំពោះបទល្មើសដែលត្រូវពាក់ព័ន្ធ ។

២. បទបញ្ញត្តិទាំងនេះមិនត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តិក្រោយការធ្វើបត្យាបន៍ឡើយ ។

## ប្រការទី ១៥
## ការប្រគល់នូវទ្រព្យសម្បត្តិ

១. ក្នុងក្របខណ្ឌនៃច្បាប់របស់ប្រទេសខ្លួន និង យោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និង ក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិៈ

ក. ដែលអាចតំរូវឱ្យធ្វើជាភស្តុតាង ឬ

ខ. ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស ។

២.ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះត្រូវរឹបអូស ឬ ប្រគល់ជូនស្របតាមកថាខ័ណ្ឌខាងលើទោះបីជាបត្យាប័នដែលត្រូវបានផ្តល់ឱ្យ មិនអាចអនុវត្តបានដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬ ការគេចខ្លួននៃជនដែលត្រូវជាប់ចោទ ។

៣. កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មសិទ្ធិនៃការដកហូត ឬ រឹបអូសនៅលើដែនដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬ បញ្ជូនវាត្រឡប់ទៅវិញ ក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនេះស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ ។

៤.រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើ ឬ រដ្ឋណាមួយ ឬ បុគ្គលណាមួយមានលើទ្រព្យសម្បត្តិដូចពោលខាងលើត្រូវបានរក្សាទុក ។ ក្រោយពីមានការជំនុំជំរះរួច ទោះជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះនៅទីណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើតាមសំណូមពរនៃភាគីនេះភ្លាមដោយគ្មានបន្ទុកពន្ធអាករ បន្ទាប់ពីការជំនុំជំរះក្តី ។

## ប្រការទី ១៦
## ដំណើរឆ្លងកាត់

១. នៅពេលដែលជនម្នាក់ត្រូវបានធ្វើបត្យាប័នបញ្ជូនពីរដ្ឋទីបីមកភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ភាគីដំបូងត្រូវស្នើសុំការ

អនុញ្ញាត្តិឆ្លងកាត់ពីភាគីម្ខាងទៀត ។ ការអនុញ្ញាត្តិបែបនេះ មិនត្រូវទាមទារទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំសំចតលើទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ។

២. ភាគីទទួលសំណើ ត្រូវផ្តល់ជូនតាមសំណើនៃការសុំឆ្លងកាត់ដែលត្រូវបានស្នើដោយភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត លើកលែងតែការឆ្លងកាត់នេះមិនផ្ទុយពីច្បាប់ក្នុងប្រទេសខ្លួន ។

## ប្រការទី ១៧
## ការផ្តល់ពត៌មានអំពីលទ្ធផល

ភាគីដាក់សំណើត្រូវបញ្ជូនដំណឹងទៅភាគីទទួលសំណើ ឱ្យបានទាន់ពេលវេលានូវដំណឹងដែលពាក់ពន្ធ័ដល់ការចោទប្រកាន់ ការជំនុំជំរះ និង ការអនុវត្តន៏នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬ ពាក់ពន្ធ័ដល់ការធ្វើបត្យាបន៍បន្ត ចំពោះជនរូបនោះទៅរដ្ឋផ្សេងទៀត ។

## ប្រការទី ១៨
## ការឧបត្ថម្ភ និង ការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើដោយចាត់ចែង និង អនុវត្តរាល់នីតិវិធីដែលចេញពីសំណើបត្យាបន៍ ។

២.ចំណាយសំរាប់បត្យាបន៍ ជាបន្ទុករបស់ភាគីដែលចំណាយនេះកើតឡើង ។ ចំណាយសំរាប់ការដឹកនាំតាមផ្លូវអាកាស និងការឆ្លងកាត់ដែលទាក់ទងនឹងការធ្វើបត្យាបន៍ជននោះ គឺជាបន្ទុករបស់ភាគីដាក់សំណើ ។

## ប្រការទី ១៩
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

សន្ធិសញ្ញានេះគ្មានប៉ះពាល់ផលដល់សិទ្ធិ និង កាតព្វកិច្ចទាំងឡាយដែលគូភាគីចុះកិច្ចព្រមព្រៀងបានទទួល និង គោរពក្នុងក្របខណ្ឌនៃអនុសញ្ញាពហុភាគីណាមួយឡើយ ។

## ប្រការទី ២០
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃសន្ធិសញ្ញានេះត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## ប្រការទី ២១
## ការធ្វើវិសោធនកម្ម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីចុះកិច្ចព្រមព្រៀងណាមួយ ។ រាល់វិសោធនកម្មដែលបានយល់ព្រមដោយភាគីចុះកិច្ចព្រមព្រៀងតាមរយៈការពិគ្រោះផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែកមួយ រួមជាមួយនឹងកិច្ចព្រមព្រៀងនេះ ។

## ប្រការទី ២២
## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និង សុពលភាពនៃសន្ធិសញ្ញា

១. សន្ធិសញ្ញានេះត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាប័ន ។ លិខិតូបករណ៍នៃការធ្វើសច្ចាប័នត្រូវប្តូរគ្នានៅភ្នំពេញ ។ សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលនៃការប្តូរលិខិតូបករណ៍នៃការធ្វើសច្ចាប័ន ។

២. ភាគីនៃកិច្ចព្រមព្រៀងនីមួយៗអាចបញ្ចប់សន្ធិសញ្ញានេះបាន ដោយផ្ដល់ដំណឹងជាលាយល័ក្ខអក្សរ ទៅភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតតាមរយៈផ្លូវទូត ។ សន្ធិសញ្ញានេះនឹងស្ថិតនៅជាធរមាន រហូតរយៈពេល៦ខែក្រោយពេលដែលភាគីម្ខាងទៀត ទទួលបានការផ្ដល់ពត៌មានស្ដីពីការបញ្ចប់នេះ ។ ការបញ្ចប់នៃសន្ធិសញ្ញានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាប័ននានា ដែលចាប់ផ្ដើមអនុវត្តមុន ការបញ្ចប់សន្ធិសញ្ញានេះឡើយ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋសាមីរៀងៗខ្លួន បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើជាពីរច្បាប់ នៅ ប៉េកាំង ថ្ងៃទី ...០៩... ខែ កុម្ភៈ ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបប្រាំបួន ជាភាសាខ្មែរ ភាសាចិន និង ភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមាន ការបកស្រាយខុសគ្នាអត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

តំណាងព្រះរាជាណាចក្រកម្ពុជា



តំណាងសាធារណរដ្ឋប្រជាមានិតចិន

